ព័ត៌មានសហគមន៍នេសាទនៅតំបន់ឆ្នេរ

# សហគមន៍នេសាទកំពង់ត្រឡាច ខេត្តកែប (២០២១)

## ស្ថានភាពទូទៅ

សហគមន៍នេសាទកំពង់ត្រឡាចមានទីតាំងស្ថិតនៅភូមិកំពង់ត្រឡាច សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប។ សហគមន៍នេសាទនេះមានផ្ទៃដីទំហំ៤២២ហិកតា មានសមាជិកសរុបចំនួន ៨៥នាក់ (ស្រី១១នាក់) និងមានសមាជិកគណៈកម្មការសហគមន៍នេសាទចំនួន០៥នាក់ (ស្រី០១នាក់)។



**ការគាំទ្រពីអ្នកពាក់ព័ន្ធ**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- រដ្ឋបាលជលផល
- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកែប
- ខណ្ឌរដ្ឋបាលជលផលខេត្តកែប
- មន្ទីរបរិស្ថានខេត្តកែប
- មន្ទីរទេសចរណ៍ខេត្តកែប
- អាជ្ញាធរមូលដ្ឋាន

**ដៃគូអភិវឌ្ឍន៍/អង្គការមិនមែនរដ្ឋាភិបាល**

- មិនមានព័ត៌មាន

**កាលបរិច្ឆេទបង្កើតសហគមន៍ ៖** ឆ្នាំ២០១០

**ការចុះបញ្ជី៖** បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣។

**ព័ត៌មានទំនាក់ទំនង**

**ទូរស័ព្ទ៖** (+៨៥៥) ៩៧ ៧០០ ៨៩៤
(+៨៥៥) ៩០ ៥៥៥ ៤២៤
**អាសយដ្ឋាន៖** ភូមិកំពង់ត្រឡាច សង្កាត់ព្រៃធំ ក្រុងកែប ខេត្តកែប។

**ឯកសារយោង៖**

- លក្ខន្តិកៈសហគមន៍នេសាទកំពង់ត្រឡាច
- បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទកំពង់ត្រឡាច
- ផែនទីសហគមន៍កំពង់ត្រឡាច
- កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍កំពង់ត្រឡាច
- ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កំពង់ត្រឡាច
- ប្រកាសលេខ១៤០ ស្ដីពីការចុះបញ្ជីសហគមន៍នេសាទ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៣

## មុខរបរចិញ្ចឹមជីវិត

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍រួមមាន៖

- ធ្វើនេសាទចំនួន៨១គ្រួសារ
- ធ្វើស្រែចំនួន២៨៨គ្រួសារ
- ដាំបន្លែចំនួន៧២គ្រួសារ
- លក់ដូរចំនួន០៣គ្រួសារ
- ចិញ្ចឹមសត្វចំនួន៥១៣គ្រួសារ
- កម្មករចំនួន៦០គ្រួសារ
- ចំណាកស្រុកនៅក្នុងប្រទេសចំនួន១០១គ្រួសារ
- ចំណាកស្រុកក្រៅប្រទេសចំនួន២៥គ្រួសារ

## ជនជាតិ និងសាសនា

**ជនជាតិ៖** ខ្មែរ ១០០ភាគរយ
**សាសនា៖** ព្រះពុទ្ធសាសនា ១០០ភាគរយ

## ប្រជាសាស្ត្រ

ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍៖ ៥៧០គ្រួសារ ស្មើនឹង២.១១៩នាក់ (ស្រី១.០៥០នាក់)

## អ្នកនេសាទ

ចំនួនអ្នកនេសាទដែលជាសមាជិកសហគមន៍៖ ១១៦នាក់ ((ស្រី ២១នាក់)
ចំនួនអ្នកនេសាទមិនមែនជាសមាជិកសហគមន៍ដែលរស់នៅក្នុងសហគមន៍សរុប៖ ២.០០៣ គ្រួសារ
ចំនួនអ្នកនេសាទដែលមកពីខាងក្រៅសហគមន៍សរុប៖ ១២នាក់



## ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវបានរៀបចំឡើងដោយអនុលោមតាមប្រការ២៣ នៃប្រកាសស្តីពីគោលការណ៍ណែនាំ អំពីសហគមន៍នេសាទរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយផ្អែកលើមូលដ្ឋានព័ត៌មានពាក់ព័ន្ធនឹងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាពលរដ្ឋ ការនេសាទ និងកសិកម្ម លក្ខណៈនៃដែននេសាទ សកម្មភាពពាក់ព័ន្ធនឹងការនេសាទ និងបញ្ហាដែលកើតមាននៅក្នុងសហគមន៍។ សហគមន៍នេសាទកំពង់ត្រឡាចបានរៀបចំផែនការបីឆ្នាំ សម្រាប់ឆ្នាំ២០២១-២០២៣។ ផែនការនេះបានបង្ហាញនូវទស្សនៈវិស័យរយៈពេលបីឆ្នាំ ដែលអាចរួមចំណែកក្នុងការធានាបាននូវការអភិវឌ្ឍសហគមន៍ប្រកបដោយចីរភាព។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ផ្តោតសំខាន់លើការប្រើប្រាស់ឧបករណ៍នេសាទ ការបោះបង្គោលព្រំប្រទល់កន្លែងសហគមន៍និងកន្លែងអភិរក្ស ការបោះស្លាកសញ្ញានិងប៉ាន់ណូ ការពង្រឹងសកម្មភាពល្បាត ការពង្រឹងសមត្ថភាពដល់គណៈកម្មការនិងសមាជិកសហគមន៍ ការពង្រីកនិងបន្ថែមមុខរបរចិញ្ចឹមជីវិត ការសាងសង់ស្នាក់ការសហគមន៍ និងការរកប្រាក់ចំណូលសម្រាប់សហគមន៍។

**ផែនការថវិកា៖** សហគមន៍កំពង់ត្រឡាចមិនទាន់មានស្វ័យភាពថវិកានៅឡើយទេ ដោយត្រូវពឹងផ្អែកលើការចុះប្រមូលវិភាគទានប្រចាំឆ្នាំតាមគ្រួសារ និងប្រអប់មូលនិធិទ្រទ្រង់សហគមន៍។

## តំបន់ការពារ និងកន្លែងគ្រប់គ្រងជលផល

មិនមានព័ត៌មាន

## កន្លែងគ្រប់គ្រងស្មៅសមុទ្រ និងព្រៃកោងកាងរបស់សហគមន៍នេសាទ

សហគមន៍នេសាទកំពង់ត្រឡាចមានគម្រោងបោះបង្គោលព្រំដែនចំនួន៤០នៅក្នុងសហគមន៍ និងតំបន់គ្រប់គ្រង ប៉ុន្តែមិនបានបញ្ជាក់ពីទំហំ និងទីតាំងជាក់លាក់នៃតំបន់គ្រប់គ្រងនោះទេ។



## ធនធានជលផល

មច្ឆជាតិ៖ ត្រី៤៧ប្រភេទ និងវារីសត្វ៣៦ប្រភេទ។
ផលនេសាទ៖ ត្រីក្នុងមួយឆ្នាំរកបាន២.៩២០គីឡូក្រាមក្នុងមួយគ្រួសារ។

## បញ្ហាប្រឈម

- ការនេសាទខុសច្បាប់
- អនាធិបតេយ្យ និងជម្លោះដែននេសាទ

ផលិតដោយ

ជំនួយរបស់សហភាពអឺរ៉ុប

អង្គការទិន្នន័យអំពីការអភិវឌ្ឍ Open Development Cambodia

C.W.D.C.C

actionaid

សហភាពអឺរ៉ុប

ឯកសារនេះរចនាដោយអង្គការទិន្នន័យអំពីការអភិវឌ្ឍ (អូឌីស៊ី) សហការជាមួយរដ្ឋបាលជលផលនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា និងអង្គការអាកសិនអេតដោយគាំទ្រថវិកាពីសហភាពអឺរ៉ុប។ទិន្នន័យនិងព័ត៌មាននៅលើផ្ទាំងព័ត៌មានទិន្នន័យសហគមន៍នេសាទនៅតំបន់ឆ្នេរដកស្រង់ចេញពីឯកសារយោងដែលមានស្រាប់ និងមិនមែនជាការឆ្លុះបញ្ចាំងពីទស្សនៈរបស់សហភាពអឺរ៉ុបឡើយ។